# ការសំភាសន៍របស់ លោកពូ ណៃម មូន្នី

កៈ អ្នកដែរសំភាសន៍ឈ្មោះ ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ឈ្មោះ ណៃមមូន្នី

## <u>ការសង្ខេបពីប្រវត្តិរបស់លោកពូ ណៃម មូន្នី</u>

លោកពូ ណៃម មូន្នី មានអាយុ55ឆ្នាំ នៅឆ្នាំ2018 ។លោកពូ ណៃម មូន្នី មានភេទប្រុសលោកពូ ណៃម មូន្នី មានទីលំនៅបច្ចុប្បន្ន នៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានៅភ្នំពេញ។

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនពូដែរបានអោយខ្ញុំបានសំភាសន៍ពីប្រវត្តិរបស់ពូ ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថា BYU ហាសពូ ចឹង ដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់នឹងបានដឹងពីប្រវត្តិឪពុកម្តាយនឹងប្រវត្តិដូនតា ចឹងហាសពូ ចឹងពេលដែរខ្ញុំសំភាសន៍ពូហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសពូ ចឹងពូយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេពូ?

ខៈ ដក់ទៅ

កៈ បាទពូ ចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍ពូខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍ពូគឺនៅថ្ងៃទី7 ខែ2 ឆ្នាំ2018 ហើយការសំភាសន៍មួយនេះត្រូវបានធញើរឡើងនៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ បាទចឹងពូឈ្មោះពេញរបស់ពូមានឈ្មោះអីគេដែរពូ?

ខៈ ឈ្មោះ ណៃម មូន្នី

កៈ ចុះមានឈ្មោះហៅក្រៅទេពូ?

ខៈ អត់មានទេ

កៈ ចុះកាលពីក្មេងមាននរណាគេហៅឈ្មោះពូអីផ្សេងទេ?

ខ៖ កាលណុងគេហៅសេង

ក៖ ហៅឈ្មោះអីគេ?

ខ៖ កាលពីនៅតូចៗនឹងគេហៅអាតឿង

ក៖ ហៅតឿងណាពូ ចុះពូសព្វថ្ងៃនឹងពូអាយុប៉ុន្មានហើយពូ?

ខ៖ ខ្ញុំអាយុ55ឆ្នាំ

ក៖ ចុះពូកើតនៅថ្ងៃខែឆ្នាំណាដែរពូ?

ខ៖ ខ្ញុំកើតនៅឆ្នាំ1962

ក៖ ឆ្នាំ1962 ចុះខែវិញពូមានចងចាំទេ?

ខ៖ កើនៅខែ1 ថ្ងៃ2

ក៖ ចុះឆ្នាំវិញពូ ឆ្នាំខ្មែរហាស លក្ខណះថាឆ្នាំជូត ឆ្លូវ ខាល ថោះហាស?

ខ៖ អូ្ន!ខ្ញុំកើតនៅឆ្នាំរោងហោស

ក៖ អូ្ន!កើតនៅឆ្នាំរោងហោសពូ ចុះពូកើតនៅណាដែរពូ?

ខ៖ ខ្ញុំកើតនៅស្រុកកងមាស

ក៖ នៅស្រុកកងមាស ខេត្តកំពង់ចាម ចុះភូមិអី ឃុំអីដែរពូ?

ខ៖ ភូមិថ្មី ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម

ក៖ បាទពូ ចុះពូមានបងប្អូនចំនួនប៉ុន្មាននាក់ដែរពូ?

ខ៖ ខ្ញុំមានបងប្អូននៅសល់4នាក់

ក៖ មាន4មាក់ ចុះកាលពីកាលពូកគាត់នៅរស់ទាំងអស់នឹងប៉ុន្មាននាក់ដែរពូ?

ខ៖ កាលពីមុនទាំងអស់មាន7នាក់ ប៉ុន្តែស្លាប់អស់3នាក់

ក៖ ពូកគាត់ស្លាប់នៅពេលណាដែរពូ?

ខ៖ ឪពុករបស់ខ្ញុំគាត់ស្លាប់អស់3-4ឆ្នាំហើយនឹងហាស

ក៖ ប៉ុន្តែឪពុករបស់ពូវិញស្លាប់នៅពាលណាដែរពូ?

ខ៖ អាមួយនោះវាគ្រោះថ្នាក់ចរាចរណ៍ នៅត្បាតពង់ហោស

កៈ ចុះពូមានបងប្អូនស្រីប៉ុន្មាន នឹងប្រុសប៉ុន្មាននាក់ដែរពូ?

ខៈ ខ្ញុំមានតែបងស្រីតែមួយទេគឺបងស្រី

កៈ ក្រៅពីនឹងសុទ្ធតែប្រុសទាំងអស់?

ខៈ ក្រៅពីចាប់ពីខ្ញុំទៅប្រុសទាំងអស់នឹង

កៈ ចឹងពូជាកូនទី2?

ខៈ បាទឹងហើយជាកូនទី2

កៈ បាទពូអាចរៀបរាប់ប្រាប់ឈ្មោះពួកគាត់ខ្លះៗបាទទេពូ?

ខៈ ចាប់ពីខ្ញុំទៅ?

កៈ រៀបរាប់ចាប់ពីបងស្រីពូទៅហាស?

ខៈ ឈ្មោះណៃម វាណ្ណា

កៈ នឹងបងគេ?

ខៈ នឹងហើយ ឈ្មោះណៃម មុន្នី , ឈ្មោះ ណៃម ថាវី រៀបរាប់អ្នកស្លាប់ដែរទេ?

កៈ អាចរាប់ទាំងអស់ទៅពូ?

ខៈ ឈ្មោះណៃម សុខន, ណៃម សុខា មានតែប៉ុណ្ណឹង

កៈ អូ៎!មានតែប៉ុណ្ណឹងទេនោះពូ?

ខៈ បាទមានតែប៉ុណ្ណឹង

កៈ ចុះពូមានចងចាំសាច់រឿងអីជាមួយបងប្អូនរបស់ពូទេ កាលនៅក្មេងៗហាស ដូចថាលក្ខណះលេងឡឹកបាយឡ លេងចុយអីចឹងហាស?

ខៈ អូ៎!អត់ទេគ្រាន់តែខ្ញុំដឹងក្តីភ្លាម ខ្ញុំនៅនឹងចង្រ្កាន់ជុំហោស ពីព្រោះតែយើងវាអត់មានស្រី សំរាប់បងស្រីពេលដែរការរួចទៅ គេទៅនៅខាងប្តីគេទៅ

កៈ ចុះបូកាលពីនៅតូចៗហាស ពូធ្លាប់លេងអីគេខ្លះជាមួយបងប្អូនរបស់ពូដែរ កាលនៅអាយុ4-5ឆ្នាំរឺ10ឆ្នាំអីចឹងហាស?

ខៈ អូ៎!នឹងខ្ញុំធ្លាប់លេងគប់កៅស៊ូអីដែរនឹងហាស

កៈ អូ៎!លេងគប់កៅស៊ូហោសពូ?

ខ៖ លេងអីនឹងហាស

ក៖ ចុះពូធ្លាប់លេងលោតអន្ទាក់អីទេ?

ខ៖ អូ៎!អត់ដែរលឺងទេ

ក៖ លេងលោតអន្ទាកដូចជាស្រីនឹងហោសពូ?

ខ៖ នឹងហើយដូចជាស្រីនឹងហាស

ក៖ ចុះពូធ្លាប់ទៅធ្វើស្រែអីជាមួយបងប្អូនរបស់ពូទេ?

ខ៖ ធ្លាប់តា

ក៖ គេធ្វើអីគេខ្លះជាមួយបងប្អូននៅស្រែដែរពូ?

ខ៖ ធ្លាប់ទៅស្ទូងស្រូវ

ក៖ ទៅស្ទូងស្រូវ ទៅដកស្ទូងអីនឹងហោស?

ខ៖ នឹងហើយ

ក៖ ចុះពូធ្លាប់មានទៅលេងទឹក ចាប់ក្តាម ចាប់ត្រី រឺមួយក៏ទៅស្ទូចត្រីអីទេ?

ខ៖ មានធ្លាប់ចាប់ដែរ ធ្លាប់ចាប់ត្រី ចាប់ក្តាមអីដែរនឹងហាស

ក៖ បាទពេលណុងនៅណាដែរពូនៅខេត្តមែនទេពូ?

ខ៖ បាទនៅខេត្ត

ក៖ អូ៎!បាទពូ ចុះបងប្អូនរបស់ពូដែរនៅរស់សព្វថ្ងៃនឹងគាត់នៅណាដែរពូ?

ខ៖ នៅកន្លែងនឹងមាន2នាក់

ក៖ ចុះនៅណាទៀតដែរពូ?

ខ៖ នៅស្រុកមាន2នាក់

ក៖ បាទពូចុះពួកគាត់បានធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតហាស?

ខ៖ គាត់ជាកសិករណុង

ក៖ គាត់នៅស្រែ ធ្វើស្រែនឹងកសិករហោសពូ
ចុះពួកគាត់ដែរនៅភ្នំពេញពួកគាត់ធ្វើអីគេដែរ?

ខ៖ មានតែខ្ញុំនៅផ្ទះនឹងហាស

ក៖ ប៉ុន្តែនៅមួយទៀត?

ខ៖ មួយទៀតគេនៅធ្វើការងារអោយគេ នៅជីកថ្មអោយគេនឹងហាស

ក៖ បាទពូ ចុះឪពុករបស់ពូមានឈ្មោះអីគេដែរពូ?

ខ៖ ឪពុករបស់ខ្ញុំឈ្មោះ ណែម វ៉ន

ក៖ ឈ្មោះណែម វ៉ន ចុះគាត់អាយុប៉ុន្មានដែរពូ?

ខ៖ គាត់អាយុ75ឆ្នាំហើយនឹងហាស

ក៖ គាត់អាយុ75ឆ្នាំ?

ខ៖ ប៉ុន្តែគាត់ស្លាប់បាត់ហើយនឹង

ក៖ ចុះគាត់នៅដល់ឥឡូវនឹងប្រហែលជាអាយុ75ឆ្នាំហាស?

ខ៖ អត់ប្រហែលជា75ឆ្នាំហាស

ក៖ ចុះគាត់កើតនៅថ្ងៃខែឆ្នាំណាពូមានចងចាំទេ?

ខ៖ ខ្ញុំអត់ចាំទេ

ក៖ អរ ចុះគាត់កើតនៅណាពូមានដឹងទេ?

ខ៖ ឪពុករបស់ខ្ញុំហោស?

ក៖ បាទពូ?

ខ៖ គាត់កើតនៅស្រុកកងមាសនឹងតែម្តងនឹងហាស

ក៖ អូ៎!ចឹងឪពុករបស់ពូគាត់កើតនៅឆ្នាំ1943ពូ

ខ៖ បាទនឹងហើយ

ក៖ ចុះម្តាយឪពុករបស់ពូគាត់មានឈ្មោះអីគេដែរពូ?

ខ៖ ម្តាយរបស់ខ្ញុំកាត់ឈ្មោះអ៊ុក លួត

ក៖ អូ៎!គាត់ឈ្មោះ អ៊ុក លួត ចុះគាត់អាយុប៉ុន្មានដែរទៅពូ?

ខ៖ គាត់អាយុហុកជាងនឹង

កៈ  អាយុហុកជាង ចុះគាត់ហុកប៉ុន្មានដែរពូ?

ខៈ  គាត់អាយុ68ឆ្នាំនឹងហាស

កៈ  គាតអាយុ68ឆ្នាំ ចឹងគាត់កើតនៅណាដែរពូ?

ខៈ  ម្ដាយរបស់ខ្ញុំគាត់កើតនៅខេត្តនឹង

កៈ  នៅខេត្តណាដែរពូ?

ខៈ  គាត់នៅជិតនាងគង្ហីងនឹង

កៈ  អ៊ូ!នៅជិតនាងគង្ហីងហោសពូ ម្ដាយរបស់ពូគាត់កើតនៅឆ្នាំ1950

ខៈ  នឹងហើយនឹង

កៈ  បាទ ចុះឪពុករបស់ពូគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរពូ?

ខៈ  កាលពីមុនមកហោស?

កៈ  បាទពូ កាលពីមុនហាស?

ខៈ  កាលពីមុនមក គាត់ជាតាកុងកាណូត

កៈ  គាត់ជាតាកុងកាណូត ចុះឪពុករបស់ពូគាត់ស្លូត រឺមួយក៏កាចដែរពូ?

ខៈ  ឪពុករបស់ខ្ញុំគាត់មិនកាចទេណាស់

កៈ  គាត់ស្លូតហោស?

ខៈ  គាត់ដូចជាខ្ញុំចឹងហាស

កៈ  អ៊ូ!បាទពូ ចុះម្ដាយរបស់ពូគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរ?

ខៈ  ម្ដាយរបស់ខ្ញុំគាតជាអ្នកលក់បាយ

កៈ  គាត់លក់តែបាយទេហោស?

ខៈ  កាត់លក់បាយជាមួយយាយរបស់ខ្ញុំគាត់លក់បបរ

កៈ  ចុះគាត់ស្លូតរឺមួយក៏កាចដែរពូ?

ខៈ  ម្ដាយរបស់ខ្ញុំគាត់ស្លូតណាស់

កៈ ចុះពូគាត់មានធ្លាប់ធ្វើអីគេជាមួយម្ដាយឪពុករបស់ពូ
កាលពីពូនៅជាមួយពួកគាត់ហាស ដូចជាទៅស្រែចឹងហាស ធ្លាប់មានធ្វើអីជាមួយគ្នាទេ?

ខៈ មានអីមានតែទៅស្រែ ហើយឪពុករបស់ខ្ញុំអោយខ្ញុំទៅរកត្រីអីនឹងហាស

កៈ អូ៎!បាទពូចឹងហោស?

ខៈ អូ៎!រកត្រីមកអាំងចឹងទៅ រឺក៏រកមករកស៊ីអីចឹងហាស

កៈ អូ៎!ចឹងហោសពូ?

ខៈ ពេលណុងគេចែកម្នាក់កន្លះម៉ែត្រ

កៈ អូ៎!បានម្នាក់កន្លះម៉ែត្រ?

ខៈ មានទទឹង4ម៉ែត្រ ប៉ុន្តែអាបណ្ដោលមិនបាច់មើលទេនឹងហាស
បាត់ស្រមោលរាប់គីឡូដីចឹងនឹងហាស

កៈ ចឹងហោសពូ?

ខៈ មានទទឹង4ម៉ែត្រ ប៉ុន្តែមិនបាច់មើលទេ

កៈ ចុះម្ដាយឪពុករបស់ពូធ្លាប់បានប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងហាស ទៅពូដែរទេពូ?

ខៈ អត់ទេ

កៈ អត់ដែរទេហោសពូ?

ខៈ នឹងហើយអត់ដែរទេ

កៈ ចុះយាយតាខាងឪពុកនឹងពូមានស្គាល់ឈ្មោះពួកគាត់ទេ?

ខៈ យាយតាខាងឪពុកហោស?

កៈ បាទនឹងហើយពូ?

ខៈ តា ឈ្មោះតា ណៃម

កៈ ឈ្មោះតា ណៃម ចុះយាយវិញ?

ខៈ យាយឈ្មោះយាយអី

កៈ ចុះគាត់កើតនៅថ្ងៃ ខែឆ្នាំណាពូមានចងចាំទេ?

ខៈ អត់ទេ

កៈ ចុះគាត់កើតនៅណាពូមានដឹងទេ?

ខៈ គាត់កើតនៅស្រុកភូមិណុងតែម្តងនឹងហាស

កៈ អ៊ូ!បាទចុះយាយតាខាងម្តាយពូមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ យាយតាខាងម្តាយនឹងគាត់កើតនៅខេត្ត នៅខាងម្តុំនាងហើងនឹងហាស

កៈ បាទពូចឹង?

ខៈ យាយរបស់ខ្ញុំឈ្មោះយាយឡឺ

កៈ ចុះតាវិញ?

ខៈ តាឈ្មោះតា ផ្លុង

កៈ ចុះពូមកនៅទីក្រុងភ្នំពេញយូរនៅពូ?

ខៈ ខ្ញុំនៅតាំងពីឆ្នាំ1982ហោស

កៈ តាំងពីឆ្នាំ1982 រហូតដល់ឥឡូវហោស?

ខៈ បាទនឹងហើយ

កៈ នឹងឆ្នាំ1982 ចឹងពូមកនៅភ្នំពេញអស់36ឆ្នាំហើយ

ខៈ បាទភ្លេចហើយ

កៈ ចុះពូមានបងប្អូនរស់នៅក្រៅប្រទេសដែរទេ?

ខៈ អត់មានទេ

កៈ អត់មានទេហោសពូ?

ខៈ បាទអត់មានទេ

កៈ ចុះភរិយារបស់ពូគាត់មានឈ្មោះអីគេដែរពូ?

ខៈ នោះឈ្មោះកែវ ញ៉េន

កៈ ឈ្មោះ កែវ ញ៉េនហោស ចុះពូមានចងចាំថ្ងៃខែឆ្នាំដែរពូបានរៀបងាពាហ៍ពិពាហ៍ទេ?

ខៈ ខ្ញុំមានបានអីខ្ញុំបានតែសែននឹងតិចតួចនឹងហាស

កៈ ប៉ុន្តែពូមានចងចាំទេ នៅថ្ងៃ ខែឆ្នាំណាចឹងហាស?

ខ៖  ខ្ញុំមិនសូវចាំទេ

ក៖  ប៉ុន្តែដូចជាពូយកភរិយាពូ ហើយពូយកកូនភ្លាម រឺមួយក៏យ៉ាងម៉េចដែរ?

ខ៖  មិនទាន់ទេ មិនដែរយកភ្លាម មានភ្លាមទេ

ក៖  ប៉ុន្តែរំលងមួយឆ្នាំអីណាពូ?

ខ៖  នឹងហើយរំលងមួយឆ្នាំទៅពីរឆ្នាំអីនឹងហាស

ក៖  ប៉ុន្តែកូនបងរបស់ពូឥឡូវនឹងអាយុប៉ុន្មានដែរហើយនឹងហាសពូ?

ខ៖  កូនសុទ្ធតែអាយុ30ឆ្នជាងហើយនឹងហាស

ក៖  ប្រហែលជាអាយុសាមប៉ុន្មានទៅពូ?

ខ៖  អាយុ35ឆ្នាំ

ក៖  អាយុ35ឆ្នាំ អូ្ហ!បងស្រីនឹងអាយុ35ឆ្នាំហើយណាពូ?

ខ៖  នឹងហើយ

ក៖  ចឹងមានន័យថាពូយកភរិយារបស់ពូអាររយៈពេល34-36ឆ្នាំហើយណាពូ?

ខ៖  ប្រហែលប៉ុណ្ណឹង

ក៖  ចុះពូមានចងចាំថាហេតុអីបានពូស្រលាញ់មីង
ថាពូចាប់ផ្តើមស្រលាញ់មីងនៅពេលណា ហើយហេតុអីបានពូចាប់ស្រលាញ់មីងដែរពូ?

ខ៖  អានឹងដូចថាជានិស្ស័យជួបគ្នាហាស

ក៖  អូ្ហ!ចឹងហោសពូ?

ខ៖  វាចឹងហាស

ក៖  ចុះពូស្រលាញ់មីងរយៈអស់រយៈពេលប៉ុន្មានឆ្នាំបានពូចូលមីងដែរ?

ខ៖  ខ្ញុំស្រលាញ់អស់រយៈពេល2ឆ្នាំហើយនឹងហាស

ក៖  អស់រយៈពេល2ឆ្នាំហោស ចុះហេតុអីបានជាពូស្រលាញ់មីងដែរពូ
ពូអាចប្រាប់តិចបានទេ?

ខ៖ អានឹងត្រូវតែមើលចរិកគេដែរនឹងហាស
យើងមិនចេះតែឃើញភ្លាមស្រលាញ់ភ្លេតណានឹងហាស កាលខ្ញុំនៅពីក្មេង
នឹងនៅពីកំលោះខ្ញុំដើរអោនចឹងហាស

ក៖ ម៉េចចឹងដែរពូ?

ខ៖ ខ្ញុំមិនចេះមើលឃើញស្រីៗចឹងខ្ញុំដើរអោនហើយនឹងហាស ខ្ញុំខ្មាស់ស្រីៗណាស់

ក៖ បាទពូ ចុះពូមានចេះភាសាខ្មែរបានល្អប៉ុណ្ណាដែរពូ?

ខ៖ ខ្ញុំមិនសូវចេះប៉ុណ្ណាដែរនឹងហាស ខ្ញុំរៀនបានថ្នាក់ទាបហាស

ក៖ ពូរៀនបានថ្នាក់ទីប៉ុន្មានដែរពូ?

ខ៖ ពេលណុងខ្ញុំរៀនបានថ្នាក់ទី7នឹងហាស

ក៖ អូ៎!ពូរៀនបានថ្នាក់ទី7ហោសពូ ?

ខ៖ តែឥឡូវនឹងខ្ញុំសរសេរអក្សរលែងចង់កើតទៀតហើយនឹងហាស
ប៉ុន្តែគ្រាន់ថានៅមើលឃើញនៅឡើយនឹងហាស

ក៖ ចុះកាលពីពូរៀននឹងតើពូរៀននៅសាលាដែរពូ?

ខ៖ ខ្ញុំរៀននៅស្រុកណុងតែម្តង

ក៖ រៀននៅស្រុកកងមាសណុងតែម្តងហោសពូ ប៉ុន្តែឈ្មោះសាលាពូនៅចងចាំឈ្មោះទេ?

ខ៖ ឈ្មោះសាលា ភ្លេចបាត់ហើយ មកយូរដែរហើយនឹងហាស

ក៖ អូ៎!បាទពូ ចុះពូមានមិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាទេ?

ខ៖ ខ្ញុំអត់មានទេ

ក៖
ចុះកាលពីពូនៅរៀនពូធ្លាប់មានមិត្តភក្តិណាមួយចំនួនដែរបានដើរលេងជាមួយគ្នាចឹងហាស
ពូ តើមានទេ?

ខ៖ មានប៉ុន្តែអាណុងវាទៅធ្វើជាទាហ៊ាន
ហើយវាត្រូវគ្រាប់ដាច់ជើងទៅឥឡូវនឹងវានៅប៉ោយ ប៉ែតហោស ឈ្មោះ អេណាន

ក៖ ចុះពូមានចងចាំអនុស្សាវរីយ៍អីជាមួយគាត់ដែរទេពូ?

ខ៖ អូ៎!កាលណុងតែបាយទឹកអីនឹងក៏ហូបជាមួយគ្នាដែរនឹងហាស

កៈ ហូបជាមួយគ្នា ចុះមានធ្វើអីផ្សេងពីនឹងទៀតទេ លក្ខណៈដើរលេងជាមួយគ្នា ទៅស្រែងឺជាមួយគ្នាចឹងហាស?

ខៈ អូ៎!បើថាទៅស្រែដើរមែន ប៉ុន្តែបើអាថាដើរលេងអីអត់មានទេ

កៈ ចុះកាលពីពូទៅស្រែជាមួយមិត្តភក្តិរបស់ពូ តើពូធ្លាប់ធ្វើអីគេខ្លះដែរទៅពូ?

ខៈ ដើរជាមួយគ្នា តែពេលដែរគេទៅដល់ស្រែគេ គេធ្វើស្រែគេ
ពេលដែរយើងទៅដល់ស្រែយើង យើងក៏ធ្វើស្រែយើងចឹងទៅណាស់

កៈ បាទពូ ចុះពូមានចេះភាសាអីក្រៅពីភាសាខ្មែរទេពូ?

ខៈ អត់មានទាំងអស់មឹង

កៈ ចឹងពូចេះតែខ្មែរទេ?

ខៈ ខ្ញុំចេះតែខ្មែរនឹងហាស

កៈ ចុះតាំងពីក្មេងរហូតមកដល់ពេលនេះហាស
តើពូគិតថាពូធ្លាប់បានធ្វើការងារអីគេខ្លះដែរទៅពូចឹងហាសពូ?

ខៈ ពីមុនមកមុខរបររបស់ខ្ញុំជាអ្នករត់រម៉កដឹកថ្ម

កៈ ចុះពូរត់រម៉កដឹកថ្ម?

ខៈ នឹងហើយ

កៈ ចុះក្រោយមកទៀតនឹង?

ខៈ ក្រោយមកធ្លាក់ខ្លួននឹង ឈឺរហូតមកនឹងហាស

កៈ ចុះពូធ្លាប់ទៅធ្វើការងារវាលស្រែទេ ធ្វើស្រែចំការហោស?

ខៈ ធ្លាប់តា

កៈ ចុះពូធ្វើអីគេនៅស្រែចំការដែរពូ?

ខៈ បើនៅណុងមានអី មានតែដំឡូងនៅខេត្តប្រាំងអីនឹងហាស

កៈ បាទចឹងហោសពូ?

ខៈ នឹងហើយយើងដាំដំឡូងនឹង

កៈ អូ៎!នឹងធ្វើនៅចំការចុះពូធ្វើស្រែវិញពូធ្វើអីគេខ្លះដែរពូ?

ខ៖ ធ្វើស្រែនឹង ស្ទូងស្រូវនឹង

ក៖ មានដក ស្ទូងអីណាពូ?

ខ៖ នឹងហើយ ដកស្ទូងអីចឹងទៅ

ក៖ មានច្រូតកាត់ ព្រុះសំណាបអីហើយណាពូ?

ខ៖ នឹងហើយធ្វើចឹង

ក៖ ដូចជាពូធ្លាប់បើអាជីកម្មខ្លួនឯងទេ?

ខ៖ អត់ទេ

ក៖ អត់ទេ ប៉ុន្តែពូធ្លាប់មានចិញ្ចឹម មាន់ទា គោ ក្របីអីទេ?

ខ៖ មានធ្លាប់គោបានបី មេមួយ ឈ្មោះមានពីរទុកគ្រាន់យើងព្យូរស្រែនឹងហាស

ក៖ បាទចុះមាន់ ទា ជ្រូកអី ពូធ្លាប់ចិញ្ចឹមទេ?

ខ៖ នឹងបានសំរាប់ចិញ្ចឹមជីវិតនឹងហាស

ក៖ អូ៎!បាទពូ គិតថាជីវិតរបស់ពូមានការផ្លាស់ប្តូរអីគេខ្លះដែរទៅពូ?

ខ៖ គ្មានការផ្លាស់ប្តូរអីគេទេ នៅតែចឹង

ក៖ ចុះគិតថាកតាំងពីក្មេងរហូតមកដល់ពេលនេះហាស ពីក្មេងយ៉ាងម៉េច ហើយដល់ពេលមានប្រពន្ធកូននឹងយ៉ាងមេចចឹងហាស?

ខ៖ កាលពីក្មេងខ្ញុំពិបាកហើយដល់ពេលដែរខ្ញុំមកដល់ចំណាស់នឹងហើយខ្ញុំនៅតែពិបាកដដែលនឹងហាស

ក៖ ប៉ុន្តែទោះយ៉ាងម៉េចក៏ពូមានអារម្មណ៍ថា ពូចេះរកស៊ីដែរមែនទេពូ?

ខ៖ នឹងហើយ យើងខំប្រឹងដែរ តែខំទៅវាមិនរួច មិនលូតឡើងនឹងគេហាស

ក៖ ចឹងហោសពូ?

ខ៖ នឹងហើយវានៅតែក្រទៅៗ

ក៖ បាទពូចុះពូចូលចិត្តម្ហូបអីគេដែរពូ ដែរពូចូលចិត្តពិសារដែរហាស?

ខ៖ មានអីមានតែត្រីងៀត

ក៖ អូ៎!ត្រីងៀតហោសពូ?

ខ៖ នឹងហើយខ្ញុំចូលចិត្តហាស

ក៖ ចុះល្បែងប្រជាប្រិយ៍អីដែរពូគិតថាពូចចូលចិត្តលេងដែរពូ តាំងពីក្មេងហាស ដូចជាល្បែងចោលឈូង បោះអង្គុញ ទាញព្រាត លាក់កន្សែង?

ខ៖ អានឹងខ្ញុំនៅពីក្មេងៗហាស ខ្ញុំចូលចិត្តលេង

ក៖ ចឹងសំរាប់ពូមានចេះច្រៀងទេពូ?

ខ៖ អត់ចេះច្រៀងទេ

ក៖ ប៉ុន្តែពូចូលចិត្តស្តាប់បទចំរៀងទេ?

ខ៖ ខ្ញុំចូលចិត្តតា

ក៖ បទសម័យ រឺមួយក៏បទបុរាណដែរពូចូលចិត្តដែរ?

ខ៖ បទបុរាណ

ក៖ បទបុរាណណាពូ?

ខ៖ បទសម័យពិបាកភ្នែកមើលណាស់

ក៖ ចុះពូមាននរណាគេនៅក្នុងក្រុមគ្រួសាររបស់ពូចេះលេងឧបករណ៍ភ្លេងទេ?

ខ៖ អត់មានទេ

ក៖ ចុះលក្ខណះថាភ្លេងពិនពាត ភ្លេងសៀម ភ្លេងការ ភ្លេងខ្មែរអីចឹងទៅ?

ខ៖ អត់មានទេ

ក៖ ចុះផ្ទះរបស់ពូមានលក្ខណះបែបណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាស មានលក្ខណះបែបណាដែរពូ?

ខ៖ នឹងផ្ទះនឹង

ក៖ ចុះកាលពីក្មេងផ្ទះបែបណាដែរពូ?

ខ៖ នឹងកាលពីក្មេងផ្ទះវា2ជាន់ដែរនឹងវារៀងធំដែរ

ក៖ អូ៎!វារៀងធំដែរហោស ប៉ុន្តែឥឡូវនឹងផ្ទះរបស់ពូ?

ខ៖ នឹងហើយ

កៈ ចុះពូគិតថាផ្ទះរបស់ពូនឹងនរណាគេជាអ្នកសាងសងដែរពូ
ដើម្បីអោយធ្វើផ្ទះបានចឹងហាស?

ខៈ ខ្ញុំសងខ្លួនឯង

កៈ អូ្!ពូចេះធ្វើផ្ទះហោសពូ ចុះពូចេះមកពីនរណាគេដែរពូ?

ខៈ ខ្ញុំចេះមកពីឪពុករបស់ខ្ញុំ

កៈ ចឹងឪពុករបស់ពូក៏ចេះដែរ?

ខៈ បាទចេះតា

កៈ ចុះពេលដែរពូធ្វើនឹងគិតថាមានឧបករណ៍អីគេសំរាប់សាងសងផ្ទះដែរពូ?

ខៈ មានតែពូថៅ ពន្លាក់ យកមកវែវាចឹងទៅ

កៈ មានឈើមានអីចឹងហាសណាពូ?

ខៈ នឹងហើយ

កៈ ចុះពូមានជំនាញអីដែរពូគិតថាពូចេះស្ទាត់ទេ?

ខៈ ជំនាញអីទេចេះធ្វើស្ទាត់នឹង

កៈ ដូចជាពូចេះធ្វើផ្ទះមួយហើយ
ចុះមានជំនាញអីផ្សេងទៀតដូចថាលក្ខណះជំនាញធ្វើសំណាង ធ្វើអីចឹងហាស?

ខៈ នឹងសំណាង់ក៏ចេះដែរ

កៈ ចឹងហោសពូ ចុះឪពុកម្ដាយរបស់ពូគាត់ធ្លាប់បង្រៀនពីជំនាញអីទៅពូទេ?

ខៈ គ្មានទេ

កៈ អត់មានទេណាពូ?

ខៈ ខ្ញុំមានតែរៀនពីមេជាងតែម្ដង

កៈ ចុះក្ដូស្កុរត្នោត ធ្វើល្អី ធ្វើកន្ទេល ធ្វើអីមួយដែរពូគិតថាចេះចឹងហាស
ឪពុកម្ដាយរបស់ពូមានដែរបង្រៀនទេ?

ខៈ អត់ទេ

កៈ បាទពូ ចុះពេលណាដែរពូគិតថាពូលំបាកជាងគេដែរពូ?

ខ៖ ពេលលំបាកជាងគេនឹង

ក៖ ដូចជាពេលកាលពីនៅក្មេង រឺពេលដែរពលពត ដែរធ្វើអោយពូពិបាកជាងគេហាស?

ខ៖ នឹងហើយនឹងពិបាកហើយនឹង

ក៖ ចុះពូអាចចែករំលែកខ្លះៗបានទេ ពូធ្លាប់ធ្វើអីគេខ្លះដែរចឹងហាស?

ខ៖ ពេលដែរដាច់ពលពតភ្លាម ខ្ញុំចេញធ្វើទាហ៊ាន

ក៖ អូ៎!ចេញធ្វើទាហ៊ាន ពេលដែរដាច់ពលពតនឹងហោស?

ខ៖ នឹងហើយ

ក៖ កាលនៅក្នុងពលពតពូធ្វើអីគេដែរពូ?

ខ៖ ខ្ញុំជាអ្នកដាំបាយអោយកុមារ

ក៖ ចុះពេលណុងពូអាយុប៉ុន្មានដែរពូ?

ខ៖ ខ្ញុំអាយុម្ភៃជាងពេលណុង

ក៖ អូ៎!ចឹងពូធំហើយហោសពូ?

ខ៖ បាទនឹងហើយ

ក៖ ប៉ុន្តែពេលណុងពូ នៅណាគេជំលាសពូអោយទៅណា?

ខ៖ នៅលំពោហោស

ក៖ នៅលំពោនឹងនៅខេត្តកំពង់ចាមយើងនឹងហោសពូ?

ខ៖ នឹងហើយនៅណុង

ក៖ ចុះពូទៅនៅតែឯង រឺមួយក៏ពូទៅនៅជាមួយក្រុមគ្រួសារដែរពូ?

ខ៖ មិនមែនទេ គេមិនអោយយកឪពុកម្តាយទៅនៅជាមួយទេ

ក៖ ប៉ុន្តែពូគេអោយទៅនៅជាមួយមិត្តភក្តិមែនទេពូ?

ខ៖ គេមិនអោយទៅទេ ទៅជាមួយកងកុមារ ទៅមួយកងកុមារចឹងតែម្តងនឹងហាស ទៅដល់កងកុមារនឹងគេអោយលើដី ឯខ្ញុំគេអោយធ្វើជាចុងភៅ

ក៖ អូ៎!ចឹងពូស្រួលហាសណាពូ?

ខ៖ នឹងហើយ

ក៖ ពូធ្វើចុងភៅស្រួលហាសចឹង?

ខ៖ គ្មានស្រួលប៉ុន្មានទេ

ក៖ ខ្លាចគេចោទថាពូហូបនេះ ហូបនោះទៅហោសពូ?

ខ៖ ខ្លាចគេយកអាថ្លើមអោយអាំងនឹង

ក៖ អូ៎!ថ្លើមមនុស្សហោស?

ខ៖ នឹងហើយឡើងភ័យ ឡើងលិចនោមដាក់ខោហោស

ក៖ ប៉ុន្តែដូចជាគេមានយកថ្លើម នឹងបេះដូងមនុស្សមកអាំងមែន?

ខ៖ បាទមានមែននឹង បើខ្ញុំនឹងជាអ្នកអាំងអោយគេនឹង

ក៖ អូ៎!ចឹងហោសពូ?

ខ៖ ហើយធ្វើទឹកត្រីអំពិលទុំចឹងទៅ

ក៖ ចុះពូធ្វើចុងភៅនឹង ពូមានធ្វើអីនៅកន្លែងណាផ្សេងទៀតទេ?

ខ៖ អត់មានទៅណាទៀតទេ

ក៖ នៅតែណុងមួយទេណពូ?

ខ៖ នឹងហើយ

ក៖ អូ៎!រហូតទាល់តែដាច់អាពត?

ខ៖ នឹងហើយទាល់តែដាច់អាពត ពេលដែរឡើងមកលើនឹងមកគេអោយកាំភ្លើងនឹងតែម្តង

ក៖ ចុះពូធ្វើជាទាហ៊ានប៉ុន្មានឆ្នាំ បានពូឈប់ធ្វើទាហ៊ានទៅពូ?

ខ៖ តាំងពីឆ្នាំ1979 មក រហូតដល់ឥឡូវនឹង

ក៖ អូ៎!តាំងពីឆ្នាំ1979រហូតមកដល់ឥឡូវនឹងហោសពូ?

ខ៖ នឹងហើយដល់ឥឡូវនឹង

ក៖ ចុះពេលដែរពូមានគ្រួសារពូគិតថាពូមានការលំបាកអីគេខ្លះដែរពូ?

ខ៖  យើងមានជួបការលំបាកហើយ តែបើយើងមិនទៅគេនៅតែបង្ខំអោយទៅ
ដល់ពេលចឹងយើងទៅតែម្តងនឹងហាស

ក៖  អូ!បាទពូ?

ខ៖  មួយជំនាន់ណុងបើយើងមិនទៅគេបង្ខំហើយណាស់

ក៖  ចុះពេលដែរពូមានកូន នឹងក្រុមគ្រួសារពូគិតថាពូមានជួបការលំបាកអីគេខ្លះដែរទៅពូ?

ខ៖  នៅតែដដែលនឹងទៅចោលប្រពន្ធនឹងហាស

ក៖  ចឹងហោសពូ?

ខ៖  នឹងហើយ

ក៖  ចុះពូគិតថាឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរពូ?

ខ៖  បើឆ្លងកាត់ព្រៃទាំងយប់ទាំងថ្ងៃនឹងហាស

ក៖  ចឹងហោសពូ?

ខ៖  នេះមើលទៅឡើងដាច់ស្លឹកត្រចៀកហើយ នេះឡើងស្រាំលលា

ក៖  អូ!កើតអីទៅពូ?

ខ៖  ខ្សែកន្លះ បើនេះជាងកាត់សក់ដកអោយ នេះចំហាបំពង់ក នៅជាប់នឹងព្រៃត្រែងម៉ង់
ពេលដែរងើបឡើងនឹងដូលជង្គង់ក្រឹប

ក៖  ចុះនេះជាឧបសគ្គរបស់ពូ?

ខ៖  ខ្ញុំមានឧបសគ្គច្រើនណាស់ ដើរទាំងយប់ដើរទាំងថ្ងៃនឹងក៏មានដែរនឹងហាស
ចាប់ពីមេម៉ត់ណុងដើរឈប់ពេលថ្ងៃសំរាកនឹង ដល់ពេលយប់ដើរទៀតទៅ
ដើររហូតដល់ស្គន់

ក៖  អូ!ដើររហូតដល់ស្គន់ហោសពូ?

ខ៖  នឹងហើយដើរដល់ស្គន់បានឡើង

ក៖  ប៉ុន្តែអស់រយះពេលប៉ុន្មានដែរពូ?

ខ៖  រយះពេលជាងមួយខែបានដើរទៅដល់នឹងហាស

ក៖  អូ!ចឹងហោសពូ?

ខ៖ ហើយដើរមិនអោយឈប់ទេណាស់ ដើរ5ម៉ែត្រមួយៗ

ក៖ ប៉ុន្តែដើរគ្នាច្រើនរឺយ៉ាងម៉េចដែរ?

ខ៖ ដើរមួយកងនឹងហាស

ក៖ ចុះមួយកងនឹងប្រហែលជាប៉ុន្មានដែរពូ?

ខ៖ មួយកងនឹងប្រហែលជា50នាក់ជាងនឹងហាស

ក៖ ប្រហែលជា50នាក់ជាហោសពូ ចុះគេដើរមកធ្វើអីគេនៅស្តន់នឹងហោសពូ?

ខ៖ ដើរលុកព្រៃវែអាពតនឹងហាស

ក៖ អូ៎!ដើរលុកតែម្តងហោសពូ?

ខ៖ នឹងហើយឆ្លងកាត់ឧបសគ្គនឹងជូរចត់ណាស់

ក៖ ចុះនៅក្នុងក្រុមគ្រួសារពូនឹងពូមានការលំបាកយ៉ាងម៉េចដែរពូ
នៅពេលដែរពូមានក្រុមគ្រួសារហាសពូ?

ខ៖ អានឹងនៅតែចឹងដដែលនឹងហាស នៅពេលដែរគេហៅទៅទៅទៀតចឹងទៅណាស់

ក៖ ចុះសព្វថ្ងៃពូគិតថាមានឧបសគ្គអីដែរបូគិតថាពូត្រូវឆ្លងកាត់ដែរទេពូ
រឺមួយក៏ពូមានទុកលំបាកអីគេខ្លះដែរពូ?

ខ៖ ខ្ញុំមានអីមានតែធ្លាក់ខ្លួនមកដឹកថ្មនឹង មកពីដឹកថ្មនឹងធ្លាក់ខ្លួនឈឺនឹងហាស

ក៖ បាទពូ
ចុះពូគិតថាពេលណាដែរពូគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងជីវិតរបស់ពូដែរទៅពូ
?

ខ៖ គ្មានអៅក្រៅពីជួបប្រពន្ធកូនទេ

ក៖ បាទពូ
ចឹងនៅពេលដែរពូបានជួបជុំប្រពន្ធកូនជាពេលដែរធ្វើអោយពូសប្បាយជាងគេនឹងហោសពូ
?

ខ៖ បាទនឹងហើយ

ក៖ ចុះពូគិតថាតាំងពីក្មេង ពូធ្លាប់មានក្តីស្រម៉ៃថាពូចង់ធ្វើអីទេពេលដែរពូធំឡើងហាស?

ខ៖ ខ្ញុំធំឡើងចង់ធ្វើជាទាហ៊ានតែម្តងនឹងខឹងណាស់

ក៖ ចង់ធ្វើជាទាហ៊ានហោសកើតអីបានពូចង់ធ្វើជាទាហ៊ានដែរពូ?

ខ៖ វាបានសំលាប់យាយរបស់ខ្ញុំនឹងតារបស់ខ្ញុំអស់រលីង នឹងពូរបស់ខ្ញុំដែរ

ក៖ នរណាគេដែរពូ?

ខ៖ ពលពតនឹង

ក៖ ពលពតនឹងហោសពូ ចុះពូគិតថាឥឡូវនឹងដាច់ពលពតហើយ ចុះពូគិតថាបើពូចង់ធ្វើទាហ៊ានពូចង់សំលាប់នរណាគេដែរទៅពូ?

ខ៖ ខ្ញុំចង់សំលាប់អ្នកដែរស្គាល់នឹងហាស

ក៖ អូ៎!អ្នកស្គាល់ហោស ចឹងមានន័យថាពួកគាត់នៅមានរស់សព្វថ្ងៃនឹងហោសពូ?

ខ៖ អត់មានទេទៅអស់ហើយនឹងហាស

ក៖ អូ៎!ទៅអស់ហើយ ចុះពូបានសំរេចនៅគោលបំណងរបស់ពូហើយមែនទេពូ?

ខ៖ បានហើយនឹងហាស

ក៖ ពូបានធ្វើជាទាហ៊ានទៀត ចុះបើចង់អោយពូផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗនឹងពូគិតថាពូចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរពូ?

ខ៖ ដូចថាកាលពីជនាន់នេះវាស្រួលដែរហើយ កុំអោយតែវាភ្លេចរឿងដើមទៅបានហើយ

ក៖ ចុះពូមានអីចង់ផ្ដែផ្ដាំអោយពួកគាត់ខំប្រឹងរៀនសូត្រ រឺពួកគាត់ធ្វើការដើម្បីអោយពួកគាត់បានការងារល្អចឹងហាសពូ?

ខ៖ ឥឡូវនឹងវាទៅធ្វើការងារ វាគ្មានទៅរៀនសូត្រអីវា

ក៖ អូ៎!ទៅធ្វើការហោស ចុះពូមានចង់ផ្ដែផ្ដាំចង់អោយពួកគាត់មានអនាគត់អីមួយដែរល្អអីទេ?

ខ៖ នឹងខ្ញុំថាអោយវាខំប្រឹងរកស៊ីអីអោយវាឆាប់មានបានទៅណាស់

ក៖ បាទពូចឹង?

ខ៖ ចុះបើខ្ញុំវាធ្លាក់ខ្លួនក្រហើយនឹងហាស

កៈ  បាទចឹងអោយគាត់ខំប្រឹងរៀន
នឹងអោយគាត់ខំប្រឹងរកស៊ីនឹងអោយដើរតាមកន្លងធិមតាមផ្លូវរបស់ពូ
នឹងធ្វើអ្វីមួយដែរល្អចឹងហោសពូ?

ខៈ  នឹងហើយ

កៈ  ចុះមានអីផ្សេងដែរពូចង់ផ្ដែផ្ដាំទៀតទេ?

ខៈ  អស់ហើយបានហើយ

កៈ  បាទពូ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនពូដែរបានអោយខ្ញុំសំភាសន៍ពូ
នឹងបានអយខ្ញុំបាននិយាយពីប្រវត្តិរបស់ពូ
ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងសាលាដើម្បីទុកអោយពូ នឹងកូនចៅរបស់ពូ
អាចស្គាល់ពីប្រវត្តិឪពុកម្ដាយនឹងប្រវត្តិដូនតាអោយគាត់បានដឹងដែរចឹងហាសពូ
ហើយពេលក្រោយខ្ញុំមានជាសំលេងពូចឹងទៅខ្ញុំនឹងយកអោយពូចឹងហាស
នឹងពូអាចចាក់ស្ដាប់អោយកូនចៅរបស់ពូបានស្គាល់ពីប្រវត្តិរបស់ពូដែរចឹងហាស
ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនពូ ហើយខ្ញុំជូនពរអោយពូឆាប់ជាពីជំងឺ
នឹងមានសុខភាពល្អ ហើយនឹងក្រុមគ្រួសារអាចរកស៊ីមានបាន
នឹងសុខសប្បាយទាំងអស់គ្នាដែរចឹងហាសពូ បាទចឹងខ្ញុំអរគុណច្រើនពូ៕៕៕